# បទពិសោធន៍ពិសេស

អែលឌើរ រ៉ូណល អេ រ៉ាសបាន
នៃគណៈប្រធាននៃក្រុម 70 នាក់

ការធ្វើដំណើរផ្ទាល់ខ្លួនរបស់យើងនៅក្នុងឆាកជីវិតផ្ដល់ឱ្យយើង នូវបទពិសោធន៍ពិសេសៗជាច្រើនដែលបានក្លាយជាថ្មឯកនៃសេចក្ដីជំនឿ និងទីបន្ទាល់ ។

ខ្ញុំសូមបន្ថែមទីបន្ទាល់របស់ខ្ញុំ និងធ្វើជាសាក្សីនៅថ្ងៃដ៏ពិសេសនេះថា ប្រធាន ថូម៉ាស អេស ម៉នសុន គឺជាព្យាការីរបស់ព្រះអម្ចាស់នៅលើផែនដី ។ ខ្ញុំមានអំណរគុណក្នុងការមានឱកាសនេះ ដើម្បីនិយាយនៅក្នុងសន្និសទូទៅ ។

ខ្ញុំមានអំណរគុណដូចជារូបអ្នករាល់គ្នាផងដែរចំពោះបទពិសោធន៍ដែលយើងមាន នៅក្នុងសន្និសីទជាប្រវត្តិសាស្ត្រនេះនៅពេលដែលយើងគាំទ្រតាមវិធីដ៏មានរបៀបរៀបរយ និងតាមមធ្យោបាយដែលយើងបានរៀបឡើងព្យាការីថ្មីរបស់យើងគឺគណៈប្រធានទីមួយ និងពួកអ្នកដឹកនាំដទៃទៀតនៃសាសនាចក្រ ។

បទពិសោធន៍ប្រភេទនេះបានពង្រឹងដល់ទីបន្ទាល់របស់យើង ហើយបង្កើនសេចក្ដីជំនឿរបស់យើង ក្នុងចំណេះដឹងថាជាការពិតណាស់នេះគឺជាសាសនាចក្រដ៏ពិតរបស់ព្រះអម្ចាស់ ហើយជាសាសនាចក្រដែលសកម្ម ។

ការធ្វើដំណើរផ្ទាល់ខ្លួនរបស់យើង ឆ្លងកាត់ឆាកជីវិតផ្ដល់ឱ្យយើងនូវបទពិសោធន៍ពិសេសៗជាច្រើន ដែលក្លាយជាគ្រឹះនៃសេចក្ដីជំនឿ និងទីបន្ទាល់ ។ បទពិសោធន៍ទាំងនេះបានកើតមានចំពោះយើងតាមមធ្យោបាយខុសៗគ្នា និងពេលដែលមិនអាចព្យាករណ៍ទុកបាន ។ បទពិសោធន៍ទាំងនេះអាចព្រឹត្តិការណ៍ខាងវិញ្ញាណដ៏មានអនុភាព ជាព្រឹត្តិការខាងវិញ្ញាណ ឬជាឱកាសស្រាយបំភ្លឺដ៏តូចមួយ ។ បទពិសោធន៍មួយចំនួននឹងកើតឡើងជាឧបសគ្គធ្ងន់ធ្ងរ ហើយជាការសាកល្បងលំបាកៗ ដែលល្បងលសមត្ថភាពរបស់យើងដើម្បីតស៊ូយកឈ្នះលើការសាកល្បងទាំងនោះ ។ មិនថាបទពិសោធន៍នោះជាអ្វីទេ បទពិសោធន៍នីមួយៗផ្ដល់ឱ្យយើងនូវឱកាសរីកចំរើនផ្ទាល់ខ្លួន ប្រាជ្ញាដ៏មហិមា និងនៅក្នុងករណីជាច្រើនធ្វើឱ្យមានការបំរើដល់អ្នកដទៃប្រកបដោយការយល់ចិត្ត និងសេចក្ដីស្រឡាញ់ ។ នៅពេលដែលព្រះអម្ចាស់បានថ្លែងទៅកាន់ ព្យាការីយ៉ូសែប ស្ម៊ីធ តាមរបៀបធ្វើការបញ្ជាក់ជាថ្មីនៅអំឡុងពេលឧបសគ្គដ៏ធំរបស់លោកនៅក្នុងគុគលិបបើធីថាៈ "គ្រប់ការណ៍ទាំងនេះនឹងផ្ដល់ការពិសោធន៍ដល់អ្នក ហើយនឹងទៅជាការល្អដល់អ្នកវិញ" ( គ. និង ស. 122:7) ។

នៅពេលដែលបទពិសោធន៍កើនឡើងនៅក្នុងជីវិតរបស់យើង វាបង្កើននូវកម្លាំង និងការគាំទ្រដល់គ្នាទៅវិញទៅមក ។ គឺដូចជាគ្រឹះនៃគេហដ្ឋានរបស់យើងជួយទ្រដល់រចនាសម្ព័ន្ធផ្សេងៗទៀត ដូច្នេះដែរ តើបទពិសោធន៍ជីវិតផ្ទាល់ខ្លួនរបស់យើងក្លាយជាគ្រឹះសំរាប់ទីបន្ទាល់របស់យើង ហើយបន្ថែមសេចក្ដីជំនឿរបស់យើងលើព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទ ដែរឬទេ ។

សម័យសន្និសិទដ៏ធំនេះបង្ហាញនូវតម្លៃជីវិតដ៏ពេញលេញដោយបទពិសោធន៍ទាំងឡាយ ។ នៅពេលយើងធ្វើតាមពាក្យប្រឹក្សាដ៏ឆ្លាតវៃរបស់ពួកអ្នកដឹកនាំ ហើយស្ងប់ស្ងែងចំពោះការបង្រៀន និងស្មារតីរបស់ពួកលោក តើអ្នករាល់គ្នាមានឆ្ងល់ទេដែលថាព្រះអម្ចាស់ជ្រើសរើសសាវកច្បងរបស់ទ្រង់ បន្ទាប់ពីត្រូវបានរៀបចំជាច្រើនឆ្នាំ ដើម្បីឱ្យធ្វើជាព្យាការីជំរើសទ្រង់?

ពរលោកអយ្យកោរបស់ខ្ញុំចង្អុលបង្ហាញថា ខ្ញុំនឹងត្រូវប្រទានឱ្យនូវបទពិសោធន៍ពិសេសដែលនឹងពង្រឹងទីបន្ទាល់របស់ខ្ញុំ។ បងប្អូនប្រុសស្រី សូមគិតពីបទពិសោធន៍ពិសេសៗដែលអ្នកបានទទួលពរជ័យនៅក្នុងជីវិតរបស់អ្នក ដែលបានធ្វើឱ្យអ្នកជឿជាក់ និងរីករាយនៅក្នុងដួងចិត្តរបស់អ្នក។ តើមាននៅចាំអំពីការដែលអ្នកបានដឹងថាលោក យ៉ូសែប ស្ម៊ីធ គឺជាព្យាការីរបស់ព្រះនៃការស្តារឡើងវិញដំបូងដែរឬទេ? នៅចាំពេលដែលអ្នកបានទទួលយកសំណើររបស់ម៉រ៉ូណៃ ហើយបានដឹងថាព្រះគម្ពីរមរមនដែលតាមពិតទៅ គឺជាសក្ខីបទមួយទៀតនៃព្រះយេស៊ូវគ្រីស្ទដែរឬទេ? តើនៅចាំពេលដែលអ្នកបានទទួលចម្លើយចំពោះការអធិស្ឋានក្លៀវក្លា ហើយបានដឹងថាព្រះវរបិតាសួគ៌របស់អ្នកជ្រាប ហើយស្រឡាញ់អ្នកម្នាក់ៗដែរឬទេ? នៅពេលដែលអ្នកសញ្ជឹងគិតអំពីបទពិសោធន៍បែបនោះ តើបទពិសោធន៍ទាំងនោះមិនបានផ្តល់ឱ្យអ្នកនូវស្មារតីនៃអំណរគុណ និងប្តេជ្ញាចិត្តដើម្បីឆ្ពោះទៅមុខជាមួយនឹងការប្តេជ្ញា និងការតាំងចិត្តជាថ្មីដែរឬទេ?

កន្លងហួសមិនយូរប៉ុន្មាន ស៊ិស្ទើរ រ៉ាសបាន និងខ្ញុំបានមាននូវបទពិសាធន៍មួយដែលយើងនឹងមិនអាចបំភ្លេចបានឡើយ។ ខ្ញុំបានទទួលការចាត់តាំងមួយដើម្បីដឹកនាំសន្និសីទស្តេកចំនួនពីរនៅប្រទេសពេរ៉ូ។ ខណៈពេលដែលនៅទីនោះ យើងបានទៅទីក្រុង ពូណូ ដ៏ខ្ពស់នៅភ្នំ អានឌីស នៅបឹង ធីធីកាកា។ នៅទីដ៏ខ្ពស់នៃបឹង អេនឌីន នេះ ដែលមានកំពស់ 3,660 ម៉ែត្រពីសមុទ្រ យើងបានមានការស្ញប់ស្ញែងចំពោះទីក្រុងដ៏សាមញ្ញ ហើយស្រស់ស្អាតនេះ ជំរៅបឹង អានឌីន។ យើងបានជួបជាមួយប្រធានស្តេកទាំងឡាយនៅក្នុងតំបន់នោះ ហើយបានធ្វើការប្រជុំពិសេសជាមួយយុវវ័យរាប់រយនាក់មកពីតំបន់ ពូណូ។

នៅព្រឹកមួយ យើងបានត្រូវអញ្ជើញឱ្យទៅសួរសុខទុក្ខក្រុមតូចមួយនៃសមាជិកនៅក្នុងមូលដ្ឋានដែលបានរស់នៅលើកោះត្រែងអណ្តែតនៃបឹងធីធីកាកា។ ប្រជាជនដែលរស់នៅទីនោះត្រូវបានគេស្គាល់ជាពួកឥណ្ឌា យូរ៉ូស នៃប្រទេសបូលីវ៉ា និងពេរ៉ូ។

យើងត្រូវបានប្រាប់ថា ក្រុមគ្រួសារពួកបរិសុទ្ធថ្ងៃចុងក្រោយពីរបីគ្រួសារ បានចូលរួមជាមួយគ្នា ហើយបានសាងសង់កោះលិចទឹកដ៏តូចនេះ។ ដោយការរំភើបរីករាយ យើងបានជិះទូកទៅកោះនោះ ហើយបានទទួលការស្វាគមន៍យ៉ាងកក់ក្តៅដោយពួកសមាជិកដ៏ល្អទាំងនេះ។

យើងបានពរទារករបស់ពួកគេដែលបានរុំកន្សែងធ្វើដោយដៃមានពណ៌ស្រស់ឆើតឆាយ។ យើងបានបរិភោគត្រីដែលពួកគេបានចាប់ថ្មីៗមកពីបឹងដែលបានចំអិនយ៉ាងយកចិត្តទុកដាក់ ហើយបានចែកចាយយ៉ាងសប្បុរស។ យើងបានឃើញសម្ភារៈ និងវត្ថុដែលធ្វើដោយដៃ ហើយការផ្លាស់ប្តូរអំណោយឱ្យគ្នាទៅវិញទៅមក។

នៅពេលដែលយើងទៅលេងទីនោះ យើងបានដឹងថា កូនៗរបស់ពួកគេបានចែវទូកអស់ 45 នាទីដើម្បីទៅរៀន និងមកពីរៀននៅថ្នាក់សិក្ខាសាលា និងសាលារៀនជារៀងរាល់ថ្ងៃ។ យើងក៏រំភើបដែលសមាជិកទាំងនេះ បានចេះពីព្រះគម្ពីរ និងយល់ពីព្រះគម្ពីរយ៉ាងល្អ ហើយស្រឡាញ់ព្រះគម្ពីរ។ ពួកគេមានចិត្តចង់បង្ហាញប័ណ្ណចូលព្រះវិហារបរិសុទ្ធរបស់ពួកគេដល់យើងយ៉ាងអន្ទះសារ ដែលបានទទួលអំណោយទានពិសិដ្ឋ និងបានផ្សាភ្ជាប់នៅក្នុងព្រះវិហារបរិសុទ្ធកូហាបាមបា បូលីវ៉ា ។

ពីមុនយើងចាកចេញ មានម្តាយម្នាក់បានសុំឱ្យយើងលុតជង្គង់ចុះជាមួយពួកគេ ហើយអធិស្ឋានជាក្រុមគ្រួសារ។ ខ្ញុំនៅចងចាំពីការលុតជង្គង់ចុះនៅលើអេប៉ុងត្រែងយ៉ាងល្អជាមួយនឹងពួកបរិសុទ្ធដ៏ស្មោះត្រង់ទាំងនេះ។ នៅពេលដែល

យើងលុតជង្គង់ចុះ នាងបានសុំឱ្យយើងនិយាយពាក្យអធិស្ឋាន ហើយប្រើបព្វជិតភាពមិលគីស្សាដែក ដើម្បីឧទ្ទិសដល់កោះ និងផ្ទះថ្មីរបស់ពួកគេ។

ខ្ញុំមានចិត្តរាបសារយ៉ាងខ្លាំងដែលនៅលើកោះលិចទឹកនៃបឹង ធីធីកាកា ក្រុមគ្រួសារពួកបរិសុទ្ធថ្ងៃចុងក្រោយដ៏ស្មោះត្រង់ទាំងនេះ បានសុំឱ្យខ្ញុំអធិស្ឋានសំរាប់កោះដ៏តូចនៃ អាពូ អ៊ិនធី ហើយសុំឱ្យព្រះអម្ចាស់ប្រសិទ្ធពរដល់ផ្ទះ និងក្រុមគ្រួសាររបស់ឡូហាណូ និងរបស់ ហាយ៉ាយូអ៊ី។

នៅពេលដែលខ្ញុំពិចារណាពីបទពិសោធន៍ដ៏ពិសេសនេះ ដែលព្រះអម្ចាស់បានប្រទានពរយើងឱ្យស្គាល់ពួកគេ ខ្ញុំដឹងថា គ្រឹះថ្មីបានត្រូវបន្ថែមនៅលើផ្ទះនៃសេចក្ដីជំនឿរបស់ខ្ញុំ។ ជាញឹកញាប់ ខ្ញុំបានគិតពីបទពិសោធន៍នៅ ពូណូ ទុកជាការរំលឹកមួយទៀតនៃការបំពេញនៃពររបស់ លោកអយ្យកោរបស់ខ្ញុំ។

ចេញពីអារម្ភកថានៃព្រះគម្ពីរគោលលទ្ធិ និងសេចក្ដីសញ្ញា ដែលបានសរសេរនៅឆ្នាំ 1831 ដោយទស្សទាយពីការពង្រីកនៃកិច្ចការរបស់ព្រះអម្ចាស់នៅសម័យរបស់យើង ព្រះអម្ចាស់បានបើកសម្ដែងថា:

"ប៉ុន្តែដើម្បីឱ្យមនុស្សគ្រប់រូបអាចនិយាយដោយនូវព្រះនាមនៃព្រះដ៏ជាព្រះអម្ចាស់ គឺជាព្រះអង្គសង្គ្រោះនៃពិភពលោក។ ដើម្បីឱ្យសេចក្ដីជំនឿអាចបានកើនឡើងនៅលើផែនដីផងដែរ ដើម្បីឱ្យសេចក្ដីសញ្ញាដ៏អស់កល្បជានិច្ចរបស់យើងអាចបានតាំងឡើង ដើម្បីឱ្យភាពពោរពេញនៃដំណឹងល្អរបស់យើងអាចបានប្រកាសប្រាប់ដោយពួកកំសោយ និងពួករាបទាបដល់អស់ចុងផែនដី" (គ. និង ស. 1:20--23)។

បងប្អូនប្រុសស្រីទាំងឡាយ សមាជិកទន់ខ្សោយ និងរាបទាបនៃសាសនាចក្រ ដូចជារូបអ្នក និងខ្ញុំ គឺកំពុងតែនាំយកដំណឹងល្អទៅដល់ចុងផែនដី ទៅកាន់ពូណូ ប្រទេសពេរ៉ូ និងនៅកន្លែងដ៏ឆ្ងាយៗដទៃទៀត។ សេចក្ដីជំនឿគឺកំពុងកើនឡើងនៅក្នុងចំណោមប្រជារាស្ត្រនៃសេចក្ដីសញ្ញារបស់ព្រះ ហើយខ្ញុំជឿថាគឺតាមរយៈការមានបទពិសោធន៍ដ៏មានតម្លៃផ្ទាល់ខ្លួន ទើបការកើនឡើងនៃសេចក្ដីជំនឿអាចកើនឡើងចំពោះយើងម្នាក់ៗបាន។

ប្រធាន ម៉នសុន បានមានប្រសាសន៍ថា: "[ព្រះអម្ចាស់] បញ្ជា។ ហើយចំពោះជនទាំងឡាយណាដែលប្រណិបត្តិតាមទ្រង់ ទោះបីជាពួកគេឆ្លាតវៃ ឬជាមនុស្សសាមញ្ញក្ដី ទ្រង់នឹងបើកសម្ដែងអង្គទ្រង់ផ្ទាល់នៅក្នុងការពុះពារទំនាស់ និងការទទួល រងទុក្ខដែលពួកគេនឹងជួបប្រទះ តាមរយៈការធ្វើតាមដល់ទ្រង់ ហើយ... ពួកគេនឹងរៀននៅក្នុង *បទពិសោធន៍របស់ពួកគេ ផ្ទាល់* ថាតើទ្រង់ជានរណា" (នៅក្នុង “Way of the Master” *លីអាហូណា* ខែ មករា ឆ្នាំ 2003 ទំព័រ 7 ការដកស្រង់ចេញពី Albert Schweitzer, *The Quest of the Historical Jesus* [1948], 401 ការបញ្ជាក់គឺជាការបន្ថែម)។

នៅសម័យនៃការរំលោភបំពានខាងពិភពលោកនៅក្នុងជីវិតរបស់យើងទាំងនេះ នៅពេលដែលឧបសគ្គ និងការលំបាកទាំងឡាយអាចមើលទៅហាក់ដូចជាសន្ធប់មកលើយើង សូមឱ្យយើងចងចាំពីបទពិសោធន៍ពិសេសផ្ទាល់ខ្លួនខាងវិញ្ញាណរបស់យើង។ គ្រឹះសេចក្ដីជំនឿ ហើយទីបន្ទាល់ទាំងនេះនឹងធ្វើឱ្យយើងមាននូវការជឿជាក់ និងការបញ្ជាក់ជាថ្មីពីការខ្វល់ខ្វាយរបស់ព្រះវរបិតាជាទីស្រឡាញ់ ដែលគង់នៅស្ថានសួគ៌ ការខ្វល់ខ្វាយនៃព្រះអង្គសង្គ្រោះព្រះយេស៊ូវគ្រីស្ទរបស់យើង និងអំពីសាសនាចក្រពិត ហើយសកម្មដែលបានស្តារឡើងវិញរបស់ពួកទ្រង់។ ខ្ញុំសូមថ្លែងទីបន្ទាល់នៅក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ អាម៉ែន។